# សង្ខេបការរួមប្រាស្រ័យរបស់ពលរដ្ឋ

**សេចក្តីផ្តើម:**

ក្របខ័ណ្ឌការងារនៃការចូលរួមរបស់ពលរដ្ឋនេះ ត្រូវបានរៀបចំឡើងក្នុងបរិបទនៃដំណើរការ និង សកម្មភាពដីសម្បទានសង្គមកិច្ច ដែលបានស្នើឡើងនៅក្នុងពេលរៀបចំគម្រោងសាកល្បងក្នុងឃុំ៣ ក្នុងខេត្តកំពង់ចាម និង ក្រចេះ។ ក្របខ័ណ្ឌការងារនេះ ត្រូវបានរៀបចំឡើង ចេញពីលទ្ធផលនៃការពិគ្រោះយោបល់និងការរួមវិភាគទានរបស់ក្រុមអ្នកពាក់ព័ន្ធចំរុះ មកពីគ្រប់ មជ្ឈដ្ឋានរាប់ចាប់តាំងពីក្រុមគ្រួសារ និង សហគមន៍ ជាពិសេសគ្រួសារក្រីក្រ តំណាងផ្លូវការភូមិ ក្រុមប្រឹក្សាឃុំនៅក្នុងតំបន់គំរោង សាកល្បង តំណាងក្រុមការងារថ្នាក់ស្រុក(DWGs) សមាជិកគណៈកម្មាធិការបែងចែកដីធ្លីថ្នាក់ខេត្ត (PLUAC) អ.ម.រ. ថ្នាក់ ខេត្ត( នៅកំពង់ចាម និង ក្រចេះ) និងថ្នាក់ជាតិ ក៏ដូចជាការណែនាំ និង រួមចំណែករបស់តំណាង ក្រសួងដែលពាក់ព័ន្ធ (ក្រសួង ដែនដីនគរូបនិយកម្មនិងសំណង់ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ក្រសួងពាណិជ្ជកម្ម) របស់រាជរដ្ឋាភិបាល និង ម្ចាស់ជំនួយដែលចូល រួម( ធានាគារពិភព លោក និង GTZ )។ វាក៏ត្រូវបានរៀបចំឡើងដោយផ្អែកតាមគោលការណ៍ជាមូលដ្ឋានរបស់ LASED ដែលបានលើក ឡើង: អភិបាលកិច្ចល្អនិងវិធាននៃច្បាប់ - ការគាំទ្រកម្មវិធីកំណែទម្រង់ដីធ្លី - ការចូលរួមនិងយេនឌ័ - តម្លាភាព និងគណនេយ្យភាព - និរន្តរភាព។

**និយមន័យ:**

ការរួមប្រាស្រ័យរបស់ពលរដ្ឋ" អាចមានន័យមួយថា ពលរដ្ឋសាមញ្ញ និង/ឬ អង្គការសង្គមស៊ីវិល ចូលរួមដោយ ផ្ទាល់ឬដោយ ប្រយោលក្តី ក្នុងការទាមទារធ្វើឱ្យប្រសើរឡើងនូវការអនុវត្តនិងគណនេយ្យភាព។

- ក្នុងបរិបទនៃវិស័យសាធារណៈ គណនេយ្យភាពសង្គមកិច្ច សំដៅលើសកម្មភាពនិងយន្តការនានាដ៏ទូលំទូលាយនៅគ្រប់ជាន់ថ្នាក់ ដែល ពលរដ្ឋ សហគមន៍ សង្គមស៊ីវិល និងផ្នែកពត៌មាន អាចប្រើដើម្បីរក្សាបាននូវ គណនេយ្យភាព របស់មន្ត្រី រាជការសាធារណៈ។
- កិច្ចការនេះអាចត្រូវបានពង្រីកសំដៅធានានូវគណនេយ្យភាពលើរាល់ការអនុវត្តរបស់អ្នកពាក់ព័ន្ធ និងអ្នកផ្តល់សេវានានា ដែលមាន ការចូលរួមពាក់ព័ន្ធ។

**គោលដៅ**

ក្រុមរៀបចំគំរោងLASED នៃរាជរដ្ឋាភិបាលកម្ពុជា (ដោយមានការគាំទ្រពីធនាគារពិភពលោកនិង GTZ) កំពុងតែ ព្យាយាម ធ្វើកិច្ចសហប្រតិបត្តិការ ដើម្បីគាំទ្រនិងសំរបសំរួលការរៀបចំក្របខ័ណ្ឌការងារនៃការរួមប្រាស្រ័យរបស់ពលរដ្ឋ សំរាប់ការអនុវត្តគំរោង LASED ដើម្បីធានាឱ្យប្រាកដថាក្របខ័ណ្ឌការងារនេះនឹងផ្តល់មកវិញនូវ:

- **<u>ការគិតគូរប្រកបដោយប្រសិទ្ធិភាព</u>** លើករណីតម្លាភាពនិង គណនេយ្យភាព ការផ្សព្វផ្សាយពត៌មាន ការចូលរួមរបស់ អ្នកពាក់ព័ន្ធ យន្តការដោះស្រាយទំនាស់ សុទ្ធតែត្រូវបានដាក់បញ្ចូលទៅក្នុងគំរោង និង ផ្សព្វផ្សាយសំរាប់ការអនុវត្ត គំរោង។
- **<u>ការបង្កើតឱ្យមានការព្រមព្រៀងគ្នា</u>** អំពីទស្សនាទាននិងវិធីសាស្ត្រនៃការរួមប្រាស្រ័យរបស់ពលរដ្ឋ រវាងរាជរដ្ឋាភិបាល និងអ្នកដែល ពាក់ព័ន្ធនានា រួមទាំងអង្គការមិនមែនរដ្ឋាភិបាលនិងសង្គមស៊ីវិល។
- **<u>រៀបចំឧបករណ៍និងការណែនាំអំពីការរួមប្រាស្រ័យរបស់ពលរដ្ឋ</u>** ដើម្បីធ្វើឱ្យមានការរួមប្រាស្រ័យពីសង្គមស៊ីវិល អង្គការមិនមែន រដ្ឋាភិបាលនិងអ្នកពាក់ព័ន្ធនានា។

**គោលបំណង**

- ការធានាឱ្យប្រាកដថាសកម្មភាពនៅក្រោមគំរោងLASEDត្រូវបានអនុវត្តយោលទៅតាមគោលការណ៍សំខាន់ៗដែលបាន ឯកភាព រួចមកហើយ។
- ក្របខ័ណ្ឌការងារនៃការរួមប្រាស្រ័យរបស់ពលរដ្ឋនឹងនាំផ្លូវសំរាប់ការពិភាក្សា និង ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធដែល ចូល រួមនិងចាប់អារម្មណ៍ ព្រមទាំងអ្នកសង្កេតការណ៍ទាំងអស់ សំដៅធានាឱ្យប្រាកដថា រាល់សកម្មភាពទាំងអស់ត្រូវបានអនុវត្ត ទៅ ប្រកបដោយតម្លាភាព និងមានការចូលរួម ហើយនិងធានាថាស្ថាប័ននិងក្រុមការងារដែលអនុវត្តសកម្មភាពក្នុងនាមនៃរាជរដ្ឋា ភិបាល

(នៅថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក ថ្នាក់ឃុំនិងថ្នាក់ភូមិ) និងអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធមានគណនេយ្យ ភាព ចំពោះសកម្មភាព របស់ខ្លួន។

**សកម្មភាព**

ក្របខ័ណ្ឌការងារនៃការរួមប្រាស្រ័យរបស់ពលរដ្ឋណែនាំក្នុងការបង្កើត និង រក្សានូវតួនាទី និង ចំណងទាក់ទងរវាង អ្នកពាក់ព័ន្ធអនុវត្តរបស់ រាជរដ្ឋាភិបាល និង សង្គមស៊ីវិល អ.ម.រ ដែលចាប់អារម្មណ៍ និង ចូលរួម ធ្វើការបំពេញឱ្យគ្នាទៅវិញទៅមក សំដៅរួមចំណែកអនុវត្តឱ្យបានជោគជ័យ នូវដំណើរការដីសម្បទានសង្គមកិច្ច ហើយធានាបានថាគ្រួសារក្រីក្រទទួលបានដោយពេញលេញនូវ កម្មសិទ្ធដីប្រកបដោយសុវត្ថភាព និង មធ្យោបាយសម្រាប់ផលិតកម្ម។ ការកសាង និង ពង្រឹងនូវគណនេយ្យភាពសង្គម និង ស្ថាប័ន គឺជាសកម្មភាពគន្លឹះ នៃការរួមប្រាស្រ័យរបស់ពលរដ្ឋ ដែលធានាបាន នូវការផ្សព្វផ្សាយពត៌មាន ការចូលរួម តម្លាភាព និង ការដោះស្រាយទំនាស់នៅគ្រប់ជំហ៊ាននៃដីសម្បទានសង្គមកិច។ សកម្មភាពទាំងនេះ គឺផ្អែកលើការសន្ទតនៃការផ្តល់ជាបន្តបន្ទាប់ និងទាន់ពេល និង លទ្ធភាពទទួលបានពត៌មានក្នុងការបំពេញឱ្យគ្នានិងគាំទ្រ ដំណើរការ និង និតិវិធីនៃដីសម្បទានសង្គមកិច្ច (មុនពេលចាប់ផ្តើមដីសម្បទានសង្គមកិច្ច - ដំណាក់កាលកំណត់ដីរបស់រដ្ឋ - ដំណាក់កាលកំណត់អ្នកទទួលផល និង ដំណាក់កាលបែងចែកដី) ដោយៈ

- ធ្វើឱ្យប្រសើរឡើងនិងពង្រីកនូវទំនាក់ទំនងនិងការផ្សព្វផ្សាយដូចលំអិតក្នុងឧបសម្ព័ន្ធ ទី ២ ( គោលការណ៍ណែនាំអំពីការប្រកាសជូនដំណឹងជាសាធារណៈ និងគំរូនៃប្រកាស) ឧបសម្ព័ន្ធ ទី៣ ( ជូនយោបល់អំពីឯកសារទំនាក់ទនងនៃការរួមប្រាស្រ័យរបស់ពលរដ្ឋ) និង ឧបសម្ព័ន្ធ ទី៥ (សេចក្តីព្រៀងខ្លឹមសារខិតប័ណ្ណគំរូសំរាប់មុនពេលផ្តើមគំរោង)។
- វិធានការលំអិតដើម្បីលើកទឹកចិត្តនិងធានាបាននូវការចូលរួមពីមនុស្សចំនួនដ៏ច្រើន "គ្រួសារដែលទទួលពត៌មានអំពី ការសំរេចចិត្ត" នៅក្នុងឧបសម្ព័ន្ធ ទី១ (ការរួមប្រាស្រ័យរបស់ពលរដ្ឋក្នុងដំណើរការដីសម្បទានសង្គមកិច្ច)។
- រួមជាវិភាគទានដល់ការធ្វើឱ្យប្រសើរឡើងនូវតម្លាភាពនិងគណនេយ្យភាពក្នុងចំណោមអ្នករួមការងារ។

រាជរដ្ឋាភិបាលនិងស្ថាប័នដែលពាក់ព័ន្ធ (LASED គណៈកម្មាធិការបែងចែកដីធ្លីថ្នាក់ខេត្ត ក្រុមការងារថ្នាក់ស្រុក និងក្រុមប្រឹក្សា ឃុំ) គួរតែជាអ្នកផ្តល់ពត៌មានមុនគេ ព្រោះថាគំរោង LASED គឺជា កម្មវិធីរបស់រាជរដ្ឋាភិបាលសំរាប់ការបែងចែកដីធ្លី។ គប្បីខិតខំប្រឹងប្រែងឱ្យបានល្អដែរធ្វើយ៉ាងណាឱ្យស្ថាប័នពាក់ព័ន្ធនៅមូលដ្ឋាន (ក្រុមប្រឹក្សាឃុំ គណៈកម្មា ធិការផែនការនិងថវិកាឃុំនិងរដ្ឋបាលភូមិ) ដោយមិនគ្រាន់តែផ្តល់នូវឯកសារពត៌មានដល់គ្រួសារក្នុងភូមិតែប៉ុណ្ណោះនោះទេ តែក៏ត្រូវផ្តល់ដល់អ្នកតាំងទីលំនៅផងដែរ នូវឱកាសស្វែងរកការពន្យល់ជាផ្លូវការនូវខ្លឹមសារនៃឯកសារទាំងនេះទៀតផង។

គឺជាការគិតគូររៀបចំឱ្យមាន នូវការចូលរួមយ៉ាងរឹងមាំរបស់សហគមន៏ក្នុងការអនុវត្តន៏គម្រោង ដោយរៀបចំតាមវិធីមួយធ្វើឱ្យមានការចូលរួម និង គាំទ្រយ៉ាងសកម្មពីថ្នាក់ក្រោមឡើងទៅ ក្នុងដំណើរការដីសម្បទានសង្គមកិច្ច។ សហគមន៏នឹងត្រូវបានរំពឹងទុក និង រៀបចំចូលរួមប្រាស្រ័យក្នុង

- ធ្វើការពន្យល់ដល់អ្នកភូមិ និង ធ្វើឱ្យតម្លាភាពនូវដំណើរការស្មុគស្មាញនៃដីសម្បទានសង្គមកិច្ច ក្នុងកំឡុងពេលមុនពេលចាប់ផ្តើមដីសម្បទាន សង្គមកិច្ច - ដំណាក់កាលកំណត់ដីរបស់រដ្ឋ - ដំណាក់កាល កំណត់អ្នកទទួលផល និង ដំណាក់កាលបែងចែកដី។
- ធ្វើការផ្តល់នូវវេទិការសាធារណៈដល់អ្នកភូមិ តាមរបៀប(ដែលធ្លាប់មាន) ការប្រជុំជូនពត៌មានភូមិ ដើម្បីជូនដំណឹងដល់អ្នកភូមិពិភាក្សាបញ្ហា និង លើកឡើងនូវការអនុវត្តន៏មិនល្អប្រសិនបើមាន ក្នុងពេលអនុវត្តគម្រោង។
- ជួយដល់រដ្ឋអំណាចអនុវត្តគម្រោង (ក្រុមប្រឹក្សាឃុំ) និង អ.ម.រ.ក្នុងស្រុកក្នុងការអនុវត្តន៏និតិវិធីជាក់លាក់ ដូចជាការធ្វើផែនទីភូមិ ការកំណត់មុខសញ្ញាអ្នកទទួលផលប្រយោជន៏ ។ល។
- អនុវត្តយន្តការដោះស្រាយការរំលោភបំពាន និង ប្រឆាំងអំពើពុករលួយ។

ការអនុវត្តន៏នូវការរួមប្រាស្រ័យមួយដូចនេះ សហគមន៏នឹងបង្កើតដោយខ្លួនឯង នូវ ក្រុមគាំទ្រសហគមន៏ (ក.គ.ស)។ គឺមានតែក្រុមនេះហើយដែលប្រជាជនមានឱកាសពិតប្រាកដក្នុងការពិភាក្សាបញ្ហាពាក់ព័ន្ធ និង សម្តែងចេញនូវមតិផ្ទាល់ខ្លួន តាមវិធីមួយដែលភាគច្រើននៃពួកគេ មិនដែលបានបញ្ចេញជាសាធារណៈ។ ជាងនេះទៀត ក្រុមទាំងនេះ ត្រូវបានរំពឹងទុករួមចំណែកជាសំខាន់ក្នុងការកំណត់ កាត់បន្ថយ និង

ដោះស្រាយបានមួយចំណែកនូវទំនាស់ដែលកើតឡើងពីការមិនចុះសម្រុងគ្នាអំពីផលប្រយោជន៍ ដែលមិនអាចចៀសផុតក្នុងការអនុវត្ត គម្រោងដីសម្បទានសង្គមកិច្ច។ អ.ម.រ. ក្នុងស្រុក ដែលមានដែលមានប្រវត្តិរឹងមាំក្នុងការអនុវត្តន៏បានច្រើនឆ្នាំ ក្នុងការអភិវឌ្ឍន៍សហគមន៍ដោយមានការចូលរួម និង ការពង្រឹងសិទ្ធអំណាចដល់ប្រជាជន គប្បីប្រគល់អណត្តិឱ្យធ្វើជាអ្នកសម្របសម្រួល ក្នុងការបំពេញឱ្យគ្នា និង គាំទ្រដល់គោលបំណងរួមរបស់ LASED ដោយៈ ធានាបានថា អ្នកភូមិ និង សហគមន៏ ទទួលបានពតិមានប្រសើរជាង និង អាចយល់បាន ចូលរួម និង រួមប្រាស្រ័យ ជាមួយអ្នកពាក់ព័ន្ធខាងផ្នែករដ្ឋាភិបាលក្នុងដំណើរការដីសម្បទានសង្គមកិច្ច។ ធ្វើការផ្តល់នូវមធ្យោបាយបន្ថែម សម្រាប់ទំនាក់ទំនង និង ធ្វើការពន្យល់ពតិមាន និតិវិធី និង ការពង្រឹងសិទ្ធអំណាចដល់ប្រជាជនដែលចូលរួមក្នុងគ្រប់ដំណាក់កាលនៃដំណើរការ និង សកម្មភាពដីសម្បទានសង្គមកិច្ច។ អាចជួយគាំទ្រ សង្កេត និង ទំនាក់ទំនង លើការកង្វល់ និង បញ្ហាដែលកើតចេញពីប្រជាជន។ រាយការណ៏ និង រួមចំណែកធ្វើឱ្យមានសុពលភាព នូវឧប្បត្តិហេតុរំលោភ ជូនស្ថាប័ដែលទទួលខុសត្រូវ អាចឱ្យគេផ្តល់មតិត្រឡប់បានប្រសើរជាង និង ទំនាក់ទំនងស្ថាប័នពាក់ព័ន្ធ។

**សន្និដ្ឋាន**

វិធីសាស្រ្តនិងសកម្មភាពក្របខ័ណ្ឌការងារនេះនឹងត្រូវបានសង្ឃឹម(និងត្រូវការ)ថា និងបន្តិវិវត្តន៏ និងកែសំរួលនៅពេលទទួលបាននូវបទពិសោធន៏ថ្មីៗមកថែមទៀត។ យើងអាចដឹងថាក្របខ័ណ្ឌការងារបច្ចុប្បន្ននឹងរួមវិភាគទានដល់ការធ្វើឱ្យប្រសើរឡើងនូវកំរិតនៃការចូលរួមជាក់ស្តែង ធានាបានកាន់តែល្អនូវតម្លាភាព និងមានការទាក់ទងផ្តល់ពតិមានសំខាន់ពាក់ព័ន្ធដល់គ្រួសារនិងសហគមន៏ កំពុងអនុវត្តនិងនៅក្នុងដីសម្បទានសង្គមកិច្ចក្នុងលកÇណៈទៀងទាត់ និងដោយការកាត់ បន្ថយបាននូវទំនាស់ និងជំលោះផ្សេងៗ ទោះបីមិនអាចកាត់បន្ថយបានទាំងស្រុង ក៏ដោយ។ ករណីមួយចំនួនដែលលើកឡើង នឹងធានាបានការធ្វើឱ្យប្រសើរឡើងនូវគណនេយ្យភាពសង្គម នៃមន្ត្រីរាជការសាធារណៈ និង អ្នក ពាក់ព័ន្ធផ្សេងទៀត ចំពោះសហគមន៏ ដែលកំពុងអនុវត្តដីសម្បទានសង្គមកិច្ច។ គួរកត់សំគាល់ថា មានការចំាបាច់ក្នុងការលើកទឹកចិត្តឱ្យមាន ការចូលរួមឱ្យបានទូលំទូលាយពីអ្នកពាក់ព័ន្ធនិងក្រុមដែលមានការចាប់អារម្មណ៏ឱ្យចូលរួមអនុវត្តក្នុងដំណើរការដីសម្បទានសង្គមកិច្ចស្របតាម ការពង្រីកនៃគំរោង។ ការអនុវត្តន៏ដោយប្រសិទ្ធភាពនូវការរួមប្រាស្រ័យរបស់ពលរដ្ឋក្នុងដំណើរការដីសម្បទានសង្គមកិច្ច នឹងទទួលនូវ អត្ថប្រយោជន៏សម្រាប់ពង្រីកនូវកិច្ចសហការដ៏រឹងមាំរវាងរាជរដ្ឋាភិបាល និង សង្គមស៊ីវីល និង អ.ម.រ។